# មេរៀនទី ១១៨៖ ព្រះយេស៊ូវបង្រៀនពួកសិស្សឱ្យអធិស្ឋាន

## ម៉ាថាយ ៦៖៥-១៣

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/4CMh7LaEh6k

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/WYwqXxVeLws

**គោលបំណង៖ ពួកយើងអាចនិយាយទៅកាន់ព្រះបាន។**

**ខគម្ពីរចងចាំ៖ ម៉ាកុស ១១:២៤** *"ដោយហេតុនោះបានជាខ្ញុំប្រាប់អ្នករាល់គ្នាថា គ្រប់ទាំងសេចក្តី ដែលអ្នករាល់គ្នាអធិស្ឋានសូមចូរជឿថា បានហើយនោះនឹងបានមែន។"*

**ចំរៀង** ( *យូធូបលីង* )៖

១.ចូរសរសើរព្រះយេស៊ូវ https://youtu.be/PtAbR7-xroM

២.ទ្រង់ជួយឱ្យខ្ញុំសប្បាយ https://youtu.be/S6mflMXkLNc

៣.ត្រូវតែអធិស្ឋានរាល់ថ្ងៃ https://youtu.be/yXD_OmWydVk

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ហោរាដានីយ៉ែល»**



១. ចែកកុមារជាពីរក្រុម ហើយនិយាយប្រាប់កាយវិការបីក្នុងការលេងល្បែងនេះ

ក. មន្ត្រីបាប៊ីឡូន (គិត)

ខ. ដានីញ៉ែល (អធិស្ឋាន)

គ. តោ (គ្រហឹម)

- ដានីញ៉ែល ឈ្នះតោ/ តោឈ្នះមន្ត្រីបាប៊ីឡូន/ មន្ត្រីបាប៊ីឡូនឈ្នះដានីញ៉ែល

២. រើសកុមារម្នាក់ធ្វើជាអ្នកដឹកនាំក្រុម ហើយឲ្យពួកគេឈរជាជួរ ដោយបែរខ្នងដាក់គ្នា

៣. មេក្រុមត្រូវពិភាក្សាជាមួយកូនក្រុមរបស់ខ្លួន ថាពួកគេនឹងធ្វើកាយវិការមួយណា។ នៅពេលដែលគ្រូរាប់ ១ ២ ៣ ក្រុមទាំងពីរត្រូវបែរមុនមករកគ្នា នឹងបង្ហាកាយវិការរបស់ពួកគេ។

៤. ប្រសិនបើក្រុមមួយធ្វើកាយវិការរបស់តោ ហើយក្រុមមួយទៀតធ្វើកាយវិការរបស់ដានីញ៉ែល (អធិស្ឋាន) នោះក្រុមដែលធ្វើកាយវិការដានីញ៉ែល(អធិស្ឋាន) នឹងឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ការអធិស្ឋានក៏អាចជួយឲ្យយើងយកឈ្នះលើតោបានដែរ។ នេះហើយគឺជាអំណាចនៃការអធិស្ឋាន។

**៤. ការណែនាំមេរៀន**

តើប្អូនប៉ុន្មាននាក់ មានប្អូន តូចៗខ្លះ?តើប្អូនៗប៉ុន្មាន នាក់ធ្លាប់មើលថែប្អូន?ប្អូនប៉ុន្មានធ្លាប់បង្រៀនប្អូនឱ្យចេះនិយាយខ្លះ? តើប្អូនប៉ុន្មាននាក់ធ្លាប់ បង្រៀនប្អូនសើច ចេះយំ ចេះច្រៀង ចេះសរសេរ ចេះថាតាម រាំតាម និយាយតាម បង្រៀនអោយចេះអង្គុយ ចេះដើរ ចេះញុំ ។ តើប្អូនធ្លាប់បង្រៀនប្អូនៗតូចរបស់អ្នកឲ្យចេះអធិស្ឋានដែរឬទេ? តើប្អូនចេះអធិស្ឋានដែរឬទេ? មេរៀនរបស់យើងនៅថ្ងៃនេះ គឺព្រះយេស៊ូវនឹងបង្រៀន ពួកយើងពីរបៀបអធិស្ឋាន។

**៥. រឿងនៅក្នុងព្រះគម្ពីរ**

ព្រះគម្ពីរនៅថ្ងៃនេះគឺនិយាយអំពីព្រះយេស៊ូវបានបង្រៀនសិស្ស (សាវក)របស់ទ្រង់ឱ្យអធិស្ឋាន។ ការអធិស្ឋានគឺសម្រាប់ព្រះជាម្ចាស់។ នេះគឺជារបៀបដែលយើងអាចនិយាយទៅកាន់ព្រះ ហើយព្រះអាចមានបន្ទូលមកកាន់យើងវិញ។ ព្រះអង្គគឺជាព្រះវរបិតារបស់យើង។ ទ្រង់ស្រឡាញ់ និង ចង់ឮពីអ្វីដែលយើងនិយាយ

ទៅកាន់ទ្រង់។ ព្រះអង្គចង់ឱ្យយើងចូលចំពោះទ្រង់ និងទូលសុំ នូវអ្វីដែលយើងត្រូវការ ហើយទ្រង់បានសន្យាថានឹងប្រទានឱ្យ។ គ្មានអ្វីដែលយើងអាចធ្វើដើម្បីទទួលបាន ឬសមនឹងទទួលបានពីព្រះឡើយ ប៉ុន្តែទ្រង់សន្យានឹងប្រទានដល់យើងនូវ អ្វីដែលយើងត្រូវការសម្រាប់ ជីវិតរបស់យើង។

ព្រះយេស៊ូវបានបង្រៀនសិស្សទ្រង់ជាដំបូងគេនោះគឺ ពួកគេមិនគួរអធិស្ឋានដើម្បីគ្រាន់តែបង្ហាញឱ្យមនុស្សឃើញនោះទេ។ ព្រះយេស៊ូវក៏បានបង្រៀនផងដែរថា យើងមិនគួរព្យាយាមប្រើពាក្យដែលពិបាកយល់ ឬនិយាយពាក្យដដែលដើម្បីអធិស្ឋាននោះដែរ។ ពីព្រោះព្រះអង្គទ្រង់ជ្រាបនូវអ្វីដែលយើងត្រូវការ មុនពេលដែលយើងទូលសូមទៅទ្រង់ទៅទៀត។

បន្ទាប់មក ទ្រង់បានបង្រៀនពួកសិស្សពី "សេចក្តីអធិស្ឋានព្រះអម្ចាស់" ។ សូមឱ្យយើងបានអាននូវផ្នែកទី ១ នៃសេចក្តីអធិស្ឋានព្រះអម្ចាស់នៅក្នុងព្រះគម្ពីរ **ម៉ាថាយ ៦៖៩-១០** "ឱព្រះវរបិតានៃយើងខ្ញុំដែលគង់នៅ ស្ថានសួគ៌អើយ សូមឲ្យព្រះនាមទ្រង់បានបរិសុទ្ធ សូមឲ្យរាជ្យទ្រង់បានមកដល់ សូមឲ្យព្រះហឫទ័យទ្រង់ បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ។"

ពួកយើងអាចមើលឃើញថា យើងត្រូវតែចាប់ផ្តើមនូវការអធិស្ឋានរបស់យើង ជាមួយនឹងការសរសើរតម្កើងព្រះនាមទ្រង់ និង ទូលសូមឱ្យទៅតាមព្រះហឫទ័យរបស់ព្រះអង្គ។ យើងត្រូវតែគិតពីអ្វី ដែលព្រះអង្គចង់បានពីយើង ដើម្បីឱ្យយើងធ្វើតាមព្រះហឫទ័យទ្រង់បាន។

បន្ទាប់ពីយើងបានស្វែងរកព្រះហឫទ័យរបស់ព្រះហើយ សូមឱ្យយើងបានអធិស្ឋានអំពីរឿងរ៉ាវផ្ទាល់ខ្លួន, សេចក្តីត្រូវការប្រចាំថ្ងៃ ដូចជាអាហារ ការអត់ទោស និងជួយយើងឱ្យផុតពីការល្បួង។ សូមឱ្យយើងបានអាននូវ ផ្នែកទី ២ នៅក្នុងគម្ពីរ **ម៉ាថាយ ៦៖១១-១៣** "សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោស ដល់អស់អ្នកដែល ធ្វើខុសនឹងយើងខ្ញុំដែរ សូមកុំនាំយើងខ្ញុំទៅកាន់សេចក្តីល្បួងឡើយ តែសូមប្រោសឲ្យយើងខ្ញុំរួចពីសេចក្តីអាក្រក់វិញ។"

សេចក្តីអធិស្ឋានព្រះអម្ចាស់បានបង្ហាញឱ្យយើងឃើញថា ការអធិស្ឋានគឺមិនមែនគ្រាន់តែទូលសូមទៅព្រះឱ្យទ្រង់ផ្តល់នូវអ្វីដែលយើងត្រូវការនោះទេ ប៉ុន្តែក៏បានរំលឹកឱ្យយើងចាំថាយើងពិតជាត្រូវការព្រះអង្គ។ បើគ្មានព្រះទេ យើងមិនអាចរត់ចេញពីការល្បួងនៃអំពើបាបបានដែរ។ យើងត្រូវការទ្រង់ដើម្បីជួយឱ្យយើងជ្រើសរើសនូវអ្វីដែលត្រឹមត្រូវនៅក្នុងជីវិតរបស់យើង។ នេះគឺជាមូលហេតុដែលយើងត្រូវតែអធិស្ឋាន។

ព្រះចង់ឱ្យយើងចូលទៅចំពោះព្រះអង្គនៅពេលដែលយើងដួលចុះ។ យើងទូលទៅព្រះដោយប្រាប់ទ្រង់ពីអ្វីដែលយើងមិនហ៊ាននិយាយជាមួយនឹងមនុស្សផ្សេងទៀត។ ទ្រង់ចង់ឱ្យយើងទូលទ្រង់ពីរឿងរ៉ាវផ្សេងៗ ដែលយើងកំពុងគិតហើយមនុស្សនៅក្នុងពិភពលោកមិនអាចយល់បាន។ យើងអាចចូលទៅចំពោះព្រះបាននៅពេលដែលយើងត្រូវការមិត្តភក្តិម្នាក់ ឬនៅពេលណាដែលយើងត្រូវការជំនួយ។ ព្រះអង្គតែងតែយល់ពីយើងគ្រប់កាលៈទេសៈ។ យើងអាចនិយាយទៅកាន់ទ្រង់ ហើយទ្រង់តែងតែរង់ចាំស្តាប់យើងជានិច្ច!

**៦. សំនួរពិភាក្សា**

១. តើចំណុច ២ យ៉ាងដែលយើងមិនគួរធ្វើនៅពេលអធិស្ឋានគឺអ្វីខ្លះ? *(អធិស្ឋានដើម្បីគ្រាន់តែបង្ហាញទៅកាន់មនុស្ស, អធិស្ឋានដោយការប្រើពាក្យពិបាកយល់ ឬ ប្រើពាក្យដដែល)*

២. តើផ្នែកទីមួយនៃ "សេចក្តីអធិស្ឋានព្រះអម្ចាស់" បានបង្រៀនឱ្យយើងអធិស្ឋានដូចម្តេច?
*(សរសើរតម្កើងព្រះ និង ទូលសូមឱ្យទៅតាមព្រះហឫទ័យរបស់ព្រះអង្គ)*

៣. តើផ្នែកទី ២ នៃ "សេចក្តីអធិស្ឋានព្រះអម្ចាស់" បានបង្រៀនឱ្យយើងអធិស្ឋានដូចម្តេច?
*(ទូលទ្រង់ពី រឿងរ៉ាវផ្ទាល់ខ្លួន, សេចក្តីត្រូវការប្រចាំថ្ងៃ ដូចជាអាហារ ការអត់ទោស និងជួយយើងឱ្យផុតពីការល្បួង)*

៤. តើប្អូនគិតថាយើងគួរអធិស្ឋានទៅទ្រង់ទ្រង់នៅពេលណាទើបទ្រង់អាចឮយើងបាន?
*(គ្រប់ពេលវេលា)*

៥. តើយើងអាចនិយាយអ្វីខ្លះនៅពេលដែលយើងអធិស្ឋាន?
*(អ្វីគ្រប់យ៉ាង! ព្រោះព្រះអង្គទ្រង់ចង់ឱ្យយើងចូលទៅចំពោះទ្រង់ និងនិយាយទៅកាន់ទ្រង់)*

**៧. ល្បែងកំសាន្ត** **«ទាយកាយវិការ»**

សម្ភារៈដែលត្រូវការ៖ សរសេរកាយវិការ ១០ ប្រយោគក្នុងក្រដាសផ្សេងៗគ្នា( ៥កាយវិការសម្រាប់ក្រុមមួយ )ឧទាហរណ៍៖ មាន់ជិះកង់ ជ្រូកផឹកទឹក គោលង់ទឹក ទាហែលទឹក ។ល។




១. ចែកកុមារជាពីរក្រុម ហើយជ្រើសមេក្រុមម្នាក់សំរាប់ក្រុមនីមួយៗ ហើយឲ្យគេចាប់ក្រដាស៥សន្លឹក ពីគ្រូ

២.  មេក្រុមនីមួយៗត្រូវប្តូរវេនគ្នាក្នុងការធ្វើកាយវិការ ( ដោយមិននិយាយអ្វីទាំងអស់ ) តាមក្រដាសដែល គេចាប់បាន។ ពួកគេមានឱកាសទាយបាន៣ដង ក្នុងការទាយ ហើយពួកគេនឹងទទួលបាន១ពិន្ទុ នៅពេលដែលទាយត្រូវម្តង។ ប្រសិនបើសមាជិកក្រុមរបស់ពួកគេមិនអាចទាយត្រូវទេនោះ នោះក្រុមមួយទៀតមាន សិទ្ធិទាយម្តង ប្រសិនបើគេទាយត្រូវនោះគេនឹងទទួលបានពិន្ទុបន្ថែម។ បន្តលេងល្បែងនេះរហូតដល់អស់ក្រដាសកាយវិការនោះ។

៣. ក្រុមណាដែលទទួលបានពន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ព្រះយេស៊ូវគឺមិនដែលទាយពីកាយវិការរបស់ពួកយើងនោះទេ ពីព្រោះទ្រង់ជ្រាបដឹងពីសេចក្តីត្រូវការរបស់យើង។ ហើយយើងគឺតែងតែអាចអធិស្ឋានទៅកាន់ព្រះយេស៊ូវ ដើម្បីនិយាយទៅកាន់ព្រះអង្គបាន។

## ៨. ខគម្ពីរចងចាំ

**ម៉ាកុស ១១៖២៤** *“ដោយហេតុនោះបានជាខ្ញុំប្រាប់អ្នករាល់គ្នាថា គ្រប់ទាំងសេចក្តី ដែលអ្នករាល់គ្នាអធិស្ឋានសូមចូរជឿថា បានហើយនោះនឹងបានមែន។”*

## ៩. ហត្ថកម្ម            “ប្រអប់នៃការអធិស្ឋាន”

សម្ភារៈដែលត្រូវការ៖ បោះពុម្ភក្រដាហត្ថកម្ម,កូល័រទៀន,កន្រ្តៃ, ការបិត

១. ចែកក្រដាសហត្ថកម្មទៅកាន់សិស្សម្នាក់មួយសន្លឹក រួចឱ្យពួកគេផាត់ពណ៌ ឬ តុបតែងទៅតាមផ្នែកនីមួយៗដែលមានសរសេរចំនងជើងនៅក្នុងនោះ។

២. កាត់ទៅតាមគម្រូពុម្ពប្រអប់, បត់តាមគម្រូ ហើយធ្វើវាឱ្យទៅជាប្រអប់។ បិតការតាមគែមនីមួយៗ

៣. ឱ្យកុមារបោះប្រអប់របស់ពួកគេ នៅពេលដែលប្រអប់របស់ពួកគេបង្ហាញចំចំណុចណាមួយ ពួកគេត្រូវនិយាយជាពាក្យអធិស្ឋានមួយប្រយោគសម្រាប់ចំនុចនោះ។ ឧទាហរណ៍៖ បើ សិនជាប្រអប់ដែលកុមារបោះនោះបង្ហាញចំពាក្យ   “ក្រុមគ្រួសារ” ពួកគេត្រូវតែអធិស្ឋាន សម្រាប់ក្រុមគ្រួសាររបស់ពួកគេ។



៤. ឱ្យកុមារនៅតែបន្តបោះប្រអប់នៃការអធិស្ឋានរបស់ពួកគេ និងអធិស្ឋានសម្រាប់ចំនុចផ្សេងដែលមាន នៅក្នុងប្រអប់។

## ១០. ចំរៀង  ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ព្រះយេស៊ូវបានបង្ហាញពួកយើងពីរៀបក្នុងការអធិស្ឋាន, អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺ ព្រះអង្គចង់បង្ហាញជាគម្រូឱ្យយើងបានទុកព្រះជាទីមួយ។ អ្វីគ្រប់យ៉ាងដែលព្រះយេស៊ូវបានធ្វើគឺសម្រាប់ ព្រះជា ម្ចាស់ ដូច្នេះវាជារឿងធម្មតាទេដែលសេចក្តីអធិស្ឋានរបស់ទ្រង់គឺផ្តោតទៅលើការសរសើរតម្កើងនិងស្រប តាមព្រះហឫទ័យនៃព្រះ។ សូមសញ្ជឹងគិតពីការអធិស្ឋានចុងក្រោយរបស់អ្នក ប្រហែលជាអ្នក បានអធិស្ឋានលឿនពេក ដូចជា “ព្រះអង្គអើយ សូមជួយឱ្យកូនមានលុយច្រើន” ឬ “ព្រះអង្គអើយសូមជួយឱ្យកូនអត់ធ្មត់ជាមួយមិត្តភក្កិកូនឱ្យបានច្រើនជាងនេះ” ជាដើម។ វាមិនមែនជារឿងខុសនោះទេ នៅពេលដែលយើងអធិស្ឋានលឿនៗក្នុងការសុំជំនួយពីព្រះនោះ។ ប៉ុន្តែការអធិស្ឋានបែបលឿនៗ ដូច្នេះគឺបានបង្ហាញឱ្យឃើញពីទស្សនៈដែលយើងមានចំពោះព្រះ។ សូមពិចារណាពីហេតុផលនៅពីក្រោយការអធិ-ស្ឋានចុងក្រោយរបស់អ្នក។ តើអ្នកចង់រកប្រាក់បន្ថែម ឬមានការអត់ធ្មត់ជាមួយមិត្តភក្តិរបស់អ្នក ដើម្បីឱ្យអ្នកដទៃអាចមើលឃើញព្រះយេស៊ូវកំពុងតែគង់នៅក្នុងអ្នកដែរឬទេ? សូមឈប់ហើយអធិស្ឋាន ឥឡូវនេះ ដើម្បីឲ្យព្រះគឺជាផ្នែកដ៏ចំបងនៃជីវិតរបស់អ្នកនិងការអធិស្ឋានរបស់អ្នកផងដែរ។

# "ប្រអប់នៃការអធិស្ឋាន"

